# មេរៀនទី ២៨: ព្រះបង្កើតអ័ដាម និងអេវ៉ា

## លោកុប្បត្តិ ២:៤-២២

**គោលបំណង៖** ព្រះបង្កើតយើងរាល់គ្នា។

**ខគម្ពីរចងចាំ៖ លោកុប្បត្តិ ២:៧** *“ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះបានបង្កើតយើងដោយលក្ខណៈពិសេស។ សូមចំណាយពេលបន្តិចដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់សិស្សរបស់អ្នក និងពីវិធីដ៏អស្ចារ្យដែលព្រះអង្គបានបង្កើតពួកគេ។ តើមានវិធីអ្វីខ្លះដែលអ្នកអាចប្រាប់ពួកគេឱ្យដឹងថាពួកគេសំខាន់យ៉ាងណា? នៅពេលអ្នកឃើញថាអ្នកមានតម្លៃនៅក្នុងព្រះនេត្ររបស់ព្រះ អ្នកអាចបំផុសគំនិតអ្នកដទៃឱ្យទទួលយកតម្លៃរបស់ពួកគេនៅក្នុងព្រះនេត្ររបស់ព្រះផងដែរ។

**ចំរៀង៖** ១. នេះគឺជាថ្ងៃ ២.គឺជាការល្អ ៣. ក្តីសុខសាន្ត

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ស្គាល់ឈ្មោះ»

**សម្ភារៈដែលត្រូវការ៖** បាល់តូចមួយ




១. ឲ្យកុមារឈរជាជរង្វង់

២. ជុំទី១៖ សិស្សត្រូវនិយាយឈ្មោះរបស់គេ ហើយបោះបាល់ទៅកុមារណាម្នាក់។ ប្រសិនបើកុមារណាម្នាក់បោះបាល់ដោយមិនបាននិយាយឈ្មោះរបស់ខ្លួនឯង នោះគេមិនអាចលេងល្បែងនេះបានទេ។

៣. ជុំទី២៖ កុមារត្រូវនិយាយឈ្មោះខ្លួនឯង ហើយបោះបាល់ទៅកុមារណាម្នាក់ដោយនិយាយឈ្មោះកុមារម្នាក់នោះផងដែរ។ ប្រសិនបើកុមារនិយាយឈ្មោះខុសនោះគេនឹងចាញ់ល្បែងនេះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ឈ្មោះរបស់យើងម្នាក់ៗគឺពិសេស ដោយព្រោះតែព្រះជាអ្នកបង្កើតពួកយើង។

### ៤. ការណែនាំមេរៀន

ប្រសិនបើអ្នកអាចបង្កើតនូវអ្វីមួយដែលថ្មីនៅក្នុងពិភពលោកនេះ តើអ្នកនឹងបង្កើតអ្វី? តើអ្នកនឹងបង្កើត សត្វដែលមានជើង៦ឬ? ឬក៏ផ្កាចេះនិយាយ? ឬក៏ពពកដែលអាចទៅតាមអ្នកគ្រប់ទីកន្លែងបាន? នៅពេលដែលព្រះបង្កើតមនុស្សព្រះអង្គបានបង្កើតដោយពិសេសបំផុត។ ថ្ងៃនេះយើងនឹងរៀនពីរបៀបដែលព្រះបានបង្កើតយើងតាមវិធីដ៏ពិសេសបំផុត!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីព្រះបានបង្កើតពន្លឺ ដី មេឃ រុក្ខជាតិ ព្រះចន្ទ ព្រះអាទិត្យ ផ្កាយ បក្សី និងសត្វសព្វសារពើ ហើយព្រះអង្គក៏បានយកចិត្តទុកដាក់ជាពិសេសក្នុងការបង្កើតមនុស្ស។ គ្រប់របស់ទាំងអស់ព្រះបានបង្កើតឡើងគឺដោយគ្រាន់តែទ្រង់មានបន្ទូលប៉ុណ្ណោះ។ ព្រះបានមានបន្ទូលថា "ចូរឲ្យមានពន្លឺកើតឡើង" ហើយនោះក៏មានពន្លឺកើតឡើងមែន **លោកុប្បត្តិ ១:២០** ព្រះបានមានបន្ទូលថា "ចូរឲ្យមានមច្ឆាជាតិរវើកនៅក្នុងទឹកជាបរិបូរ និងបក្សីជាតិហើរលើដីនៅនាអាកាស" ហើយគ្រប់យ៉ាងក៏បានកើតឡើងដោយគ្រាន់តែព្រះមានបន្ទូលប៉ុណ្ណោះ។

ប៉ុន្តែនៅថ្ងៃទី ៦ **លោកុប្បត្តិ ១:២៦** " ទ្រង់ក៏មានព្រះបន្ទូលថា ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើងឲ្យមានភាពដូចយើង ហើយឲ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើង៤ ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅលើផែនដីផង។"

ព្រះបានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់ នេះគឺមានន័យថាយើងអាចយល់ពីព្រះហឫទ័យទ្រង់បាន។ ព្រះអង្គក៏បានឲ្យសិទ្ធិអំណាចទៅមនុស្សជាអ្នកមើលការខុសត្រូវលើរបស់សព្វសារពើដែលទ្រង់បានបង្កើតមកផងដែរ! តើនេះមិនអស្ចារ្យពេកទេឬអី? មិនត្រឹមតែប៉ុណ្ណោះ ជំនួសឲ្យការដែលទ្រង់គ្រាន់តែមានបន្ទូលហើយរបស់ទាំងអស់នោះកើតឡើង **លោកុប្បត្តិ ២:៧** ក៏បានចែងថា "ព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង។"

ព្រះបានបង្កើតយើងឡើងដោយព្រះហស្តរបស់ទ្រង់! នេះគឺមានន័យថា មិនថាយើងមានរូបរាងយ៉ាងណានោះទេ ពួកយើងគឺជាមនុស្សពិសេសដោយព្រោះព្រះជាអ្នកបង្កើតយើងមក! ហើយព្រះបានផ្លុំខ្យល់ដង្ហើមមកក្នុងខ្លួនយើង ដើម្បីឲ្យយើងមានជីវិតរស់ឡើង។ នេះគឺជាការបង្កើតដ៏អស្ចារ្យ ពីព្រោះថាគ្មានការបង្កើតណាមួយដែលទ្រង់បានផ្លុំខ្យល់ដង្ហើមឱ្យនោះទេ!

បន្ទាប់មកព្រះបានប្រាប់ទៅអ័ដាមឲ្យដាក់ឈ្មោះសត្វទាំងអស់។ អ័ដាមបានឃើញថាគ្រប់សត្វទាំងអស់គឺមានមិត្តភក្តិ និងក្រុមគ្រួសារ។ ព្រះបានដឹងថាអ័ដាមនៅម្នាក់ឯងគឺឯកាណាស់ ដូច្នេះព្រះបានដកយកឆ្អឹងជំនីរបស់អ័ដាម ហើយបានបង្កើតស្ត្រីម្នាក់សម្រាប់គាត់។ ព្រះបានដកយកឆ្អឹងជំនីអ័ដាមពីចំហៀងខ្លួនរបស់គាត់ ដើម្បីបង្កើតអេវ៉ា នេះគឺបញ្ជាក់ថាបុរសមិនខ្ពង់ខ្ពស់ជាងស្ត្រីនោះទេហើយពួកគេត្រូវជួយគ្នាទៅវិញទៅមក។ ម្យ៉ាងទៀតដោយព្រោះតែអ័ដាមបានឲ្យឆ្អឹងជំនីរបស់គាត់ដើម្បីបង្កើតជាអេវ៉ា ដូច្នេះគាត់មិនអាចពេញលក្ខណៈបានទេប្រសិនបើគ្មានអេវ៉ានោះ។ ក៏ដូចគ្នានេះ អេវ៉ាបានកើតចេញពីអ័ដាម ដូច្នេះប្រសិនបើគ្មានអ័ដាមទេ អេវ៉ាក៏មិនពេញលក្ខណៈដែរ។ ព្រះចង់ឲ្យអ័ដាម និងអេវ៉ាស្រលាញ់គ្នាទៅវិញទៅមក និងបង្កើតគ្រួសាររបស់ព្រះជាមួយគ្នា ឲ្យដូចជាពួកគេស្រលាញ់ព្រះ និងទទួលបានសេចក្តីស្រលាញ់ដែលព្រះបានប្រទានមកដល់ពួកគេផងដែរ។

នៅពេលដែលយើងក្រលេកមើលគ្រប់គ្នានៅក្នុងថ្នាក់រៀននេះ យើងឃើញថាម្នាក់ៗមានមុខមាត់ខុសៗគ្នា។ នេះគឺព្រោះតែយើងកើតមកពីការបង្កើតដ៏អស្ចារ្យ និងស្រស់ស្អាតនៃព្រះជាម្ចាស់។ សូមអ្នកសាកពិចារណាមើលថាមានមនុស្សរាប់ពាន់លាននាក់ដែលរស់នៅលើពិភពលោកនេះ។ ព្រះបានបង្កើតមនុស្សម្នាក់ៗតាមទម្រង់ និងលក្ខណៈផ្សេងៗគ្នា ដែលនេះគឺជាសិល្បៈនៃការបង្កើតដែលមានភាពច្នៃប្រឌិតខ្ពស់បំផុត! ព្រះអង្គមានអំណាច

ហើយយើងរាល់គ្នាគឺជាភស្តុតាង បញ្ជាក់ថាព្រះពោរពេញទៅដោយអំណាច ការច្នៃប្រឌិត និងសេចក្ដីស្រលាញ់។ ព្រះបានបង្កើតយើងមកដោយសេចក្ដីស្រលាញ់ ហើយទ្រង់ចង់ឲ្យយើងស្រលាញ់ព្រះអង្គ និងទទួលបានសេចក្ដីស្រលាញ់ពីទ្រង់ផងដែរ!

**៦. សំនួរពិភាក្សា**

១. តើព្រះបានបង្កើតអ័ដាម(មនុស្ស)ដោយរបៀបណា? *ព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិត នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង*

២. តើយើងអាចមើលឃើញអំណាច ការច្នៃប្រឌិត និងការបង្កើតមនុស្សរបស់ព្រះដោយរបៀបណា? *ព្រះបានបង្កើតមនុស្សដ៏ល្អនិងមានទម្រង់ខុសៗគ្នា*

៣. តើអ្នកអាចបង្ហាញពីលក្ខណៈពិសេសរបស់អ្នកដែលព្រះបានបង្កើតដែរឬទេ? *ទុកឲ្យកុមារជាអ្នកឆ្លើយ*

**៧. ល្បែងកំសាន្ត** **«លាក់មុខ»**

**សម្ភារៈដែលត្រូវការ៖** ភួយ




១. ចែកកុមារជាពីរក្រុមហើយឲ្យកុមារអង្គុយទល់មុខគ្នា

២. គ្រូនិងឈរនៅកណ្ដាលដោយដាក់ភួយនៅកណ្ដាលផងដែរ ដើម្បីកុំឲ្យក្រុមទាំងពីរមើលគ្នាឃើញ

៣. ក្រុមទាំងពីរត្រូវជ្រើសរើសកុមារណាម្នាក់ពីក្រុមទាំងពីរ មកខាងមុខជិតភួយដោយស្ងៀមស្ងាត់។ នៅពេលដែលគ្រូរាប់ ១ ២ ៣ គ្រូនិងដាក់ភួយចុះ ហើយកុមារទាំងពីរត្រូវហៅឈ្មោះគ្នាទៅវិញទៅមកឱ្យបានលឿន។ ប្រសិនបើគេហៅឈ្មោះបានត្រូវ និងលឿនជាងនោះគេនឹងទទួលបានមួយពិន្ទុ។

៤. ក្រុមណាដែលមានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះបានបង្កើតយើងទាំងអស់គ្នា ហើយដាក់ឈ្មោះដល់យើងគ្រប់ៗគ្នា។ ទោះបីជាយើងភ្លេចឈ្មោះមិត្តភក្ដិរបស់យើងក៏ដោយ តែព្រះមិនភ្លេចឈ្មោះយើងទេ ពីព្រោះព្រះបានបង្កើតយើង!

**៨. ខគម្ពីរចងចាំ** **លោកុប្បត្តិ ២:៧**

**៩. ហាត្ថកម្ម** សូមផាត់ពណ៌រូបភាព **«ព្រះបង្កើតអ័ដាម និងអេវ៉ា»**

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះបង្កើតអ័ដាម និង អេវ៉ា



លោកុប្បត្តិ ២:៧ "ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង។"